ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មការសម្រាប់ដោះស្រាយបញ្ហា
កូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
គណៈកម្មការដោះស្រាយករណីរោងចក្រ
បិទទ្វារដោយម្ចាស់រត់ចោល
អគ្គលេខាធិការដ្ឋាន
លេខ......៤៨៦......អ.គ.ក.ប

# សេចក្តីជូនដំណឹង
# ស្តីពី
# ការលក់ឡៃឡុងសម្ភារ បរិក្ខារ រោងចក្រ ប៊ីណូ អឹមភើរៃល (ខេមបូឌា) ខូអិលធីឌី

គណៈកម្មការដោះស្រាយករណីរោងចក្របិទទ្វារដោយម្ចាស់រត់ចោល មានកិត្តិយសសូមជម្រាបជូនសាធារណៈជនឱ្យបានជ្រាបថា៖ គណៈកម្មការនឹងដាក់លក់ឡៃឡុងជាសាធារណៈ នូវទ្រព្យសម្បត្តិរបស់រោងចក្រ ប៊ីណូ អឹមភើរៃល (ខេមបូឌា) ខូអិលធីឌី ដែលមានអាសយដ្ឋាន ភូមិត្នោត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយដាក់ដេញថ្លៃចាប់ពីតម្លៃអប្បបរមា **៥០ ០០០ដុល្លារ (ហាសិបពាន់ដុល្លារសហរដ្ឋអាមេរិកគត់)** ឡើងទៅ។

- <u>ការពិនិត្យមើល និងវាយតម្លៃសម្ភារបរិក្ខារ៖</u> នៅថ្ងៃទី២៨ - ៣១ ខែឧសភា ឆ្នាំ២០១៨ រៀងរាល់ម៉ោងធ្វើការ នៅក្នុងទីតាំងរោងចក្រ ប៊ីណូ អឹមភើរៃល (ខេមបូឌា) ខូអិលធីឌី ផ្ទាល់។ ក្រុមហ៊ុន សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ត្រូវភ្ជាប់មកជាមួយនូវបណ្ណប៉ាតង់ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ បញ្ជីរាយមុខសម្ភារបរិក្ខារនឹងផ្តល់ជូននៅទីតាំងរោងចក្រ ឬអាចមកទទួលពី គណៈកម្មការដោះស្រាយករណីរោងចក្របិទទ្វារដោយម្ចាស់រត់ចោល នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

- <u>កាលបរិច្ឆេទលក់ពាក្យស្នើសុំសិទ្ធិចូលរួមដេញថ្លៃ៖</u> ចាប់ពីថ្ងៃទី០៤ - ០៨ ខែមិថុនា ឆ្នាំ២០១៨ រៀងរាល់ម៉ោងធ្វើការ នៅគណៈកម្មការដោះស្រាយករណី រោងចក្របិទទ្វារដោយម្ចាស់រត់ចោល នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ទូរសព្ទទំនាក់ទំនងលេខ៖០១៦ ៥៣ ៥៣ ៨៣ ឬ០១៧ ៨០ ៧៩ ០៧)។

- <u>កាលបរិច្ឆេទទទួលពាក្យ៖</u> ចាប់ពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ រហូតដល់កាលបរិច្ឆេទបើកសំណើដេញថ្លៃ។

- <u>កាលបរិច្ឆេទបើកសំណើដេញថ្លៃ៖</u> ប្រព្រឹត្តិទៅនៅវេលាម៉ោង១៤:៣០នាទី ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០១៨ នៅសាលប្រជុំគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ដើម្បីចូលរួមដេញថ្លៃ ក្រុមហ៊ុន សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

១.ពាក្យសុំសិទ្ធិចូលរួមដេញថ្លៃ ចំនួន ០១(មួយ)ច្បាប់
២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)
៣. ប័ណ្ណប៉ាតង់ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)

__បញ្ជាក់៖__

១. ត្រូវកក់ប្រាក់ធានាការដេញថ្លៃចំនួន ១០% (ដប់ភាគរយ) នៃតម្លៃអប្បបរមាខាងលើ ឱ្យបានមុនកាលបរិច្ឆេទបើកសំណើដេញថ្លៃ។

២. មិនអាចដាក់តម្លៃដេញថ្លៃទាបជាង តម្លៃអប្បបរមាដែលបានកំណត់ខាងលើ។

៣. ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

៤. អ្នកដេញថ្លៃត្រូវដាក់តម្លៃដេញថ្លៃតែមួយគត់ ហើយជាតម្លៃថេរក្នុងរយៈពេលអនុវត្តកិច្ចសន្យារបស់ខ្លួន។ សំណើដេញថ្លៃណាមួយដែលដាក់តម្លៃដេញថ្លៃលើសពីមួយ ឬតម្លៃប្រែប្រួល ត្រូវចាត់ទុកជាមោឃៈ ។

ករណី មិនគោរពតាមលក្ខខណ្ឌកំណត់ខាងលើ គណៈកម្មការនឹងនិរាករណ៍លើសំណើសុំដេញថ្លៃ និងដកហូតប្រាក់កក់ធានាការដេញថ្លៃ ១០% ទុកជាចំណូលរដ្ឋ។

ថ្ងៃ...........................ខែ..................ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី.....២២..... ខែឧសភា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គលេខាធិការ**
**នៃ អ.គ.ភ.ប និងជាអនុប្រធានអចិន្ត្រៃយ៍**
**គណៈកម្មការដោះស្រាយករណីពោធចក្រ**
**មិនទាន់ទូទាត់រួច ឬម្ចាស់ទ្រព្យបោះបង់ចោល**

ប្រាក់ ចាន់ធឿន

ចម្លងជូន៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អង្គភាពប្រឆាំងអំពើពុករលួយ

*"ដើម្បីជូនជ្រាប"*

- ឯកសារ-កាលប្បវត្តិ